**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៣៤២

ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២

ជំនុំជម្រះ

លេខ: ៥៤៤ជចត

ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២

សាលក្រម

លេខ:១៥ "ជ"

ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅបន្ទប់សវនាការ នៃសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ:

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តតាកែវ

## តំណាងអយ្យការ

លោក[redacted]ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

## ក្រឡាបញ្ជីសវនាការ

លោក[redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

## ដើម្បីជំនុំជម្រះ

**រឿងក្តីព្រហ្មទណ្ឌលេខ: ៣៤២ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ:**

-ឈ្មោះ[redacted]**ភារម្យ** ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរអ្នកបើកឡាន កម្រិតវប្បធម៌ថ្នាក់ទី....ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ស្ពឺ និងទីលំនៅមុនពេលឃុំខ្លួនភូមិភ្នំតូច ឃុំសូភី ស្រុកបាទី ខេត្តតាកែវ ឪពុកឈ្មោះ[redacted]**ធី** (រ) ម្តាយឈ្មោះ[redacted]**ណាង**(រ) ប្រពន្ធឈ្មោះ [redacted] **ស្រីណា** មានកូនចំនួន០២នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **គ្មាន**។

**(ឃុំខ្លួនថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២)**

ជាប់ចោទពីបទ: **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួស និងស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅភូមិតាំងដូង ឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ និងមាត្រា៨៥ ច្បាប់ស្តីពីចរាចរណ៍ផ្លូវ គោក។

-ដើមបណ្តឹងឈ្មោះ [redacted] **សារ៉ន** ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិបាំងណា ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

-ដើមបណ្តឹងឈ្មោះ[redacted]**ភាស់** ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិស្រុកចេក ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។



Scanned with CamScanner

-ជនរងគ្រោះឈ្មោះ [redacted] **សារី** ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិកាយៀវ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី **និងតំណាងឱ្យក្រុមហ៊ុន** CHINA ROAD BRIDGE COPORARION (CRBC) ដែលមាអាសយដ្ឋាន# 445 Phnom Penh Tower ជាន់ទី១៩ ផ្លូវព្រះមុនីវង្ស(៩៣) កែងផ្លូវលេខ២៣២ ភូមិ១ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ដោយមានលោក ZHOU YONG ជាអ្នកតំណាង និងក្រុមហ៊ុន**ធានារ៉ាប់រង ភីភល & ផាតន័រ អ៊ិនសួរេន ភីអិលស៊ី** មានអាសយដ្ឋានផ្ទះលេខ៣៨ ផ្លូវ៣២២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានលោក [redacted] **សាមិត្ត** ជានាយកប្រតិបត្តិតំណាងឱ្យក្រុមហ៊ុន។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: **៩២២៨.ស.៣** ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ:**៥០៧**ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តតាកែវ ។

**-បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ:**៥៤៤ដចត** ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តតាកែវ ។

**-បានឃើញ** ឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១៧និង៣០នាទីព្រឹក បានបើកបររថយន្តមួយគ្រឿងម៉ាកដេវូ ពណ៌ត្រអ៊ី ពាក់ស្លាកលេខភ្នំពេញ 3A-3836 ចេញពីក្រុមហ៊ុនដឹកដីក្នុងគោលដៅឆ្ពោះទៅរាជធានីភ្នំពេញ លុះដល់ចំណុចផ្លូវជាតិលេខ៣ ចន្លោះគីឡូម៉ែត្រ លេខ៤១-៤២ ស្ថិតនៅភូមិតាំងដូង ឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ បើកបររថយន្ត ដោយខ្វះការប្រុងប្រយ័ត្ន បានបុករថយន្តមួយគ្រឿង ម៉ាកតូយ៉ូតា ពណ៌សពាក់ស្លាកលេខ ភ្នំពេញ 2BO-2620 បើកបរដោយឈ្មោះ [redacted] **រស្មី** ភេទប្រុ អាយុ២២ឆ្នាំ បណ្តាលឱ្យអ្នកបើកបរឈ្មោះ [redacted] **រស្មី** ស្លាប់នៅនឹងកន្លែងកើតហេតុចំណែកអ្នករួមដំណើរឈ្មោះ [redacted] **លាង** ភេទប្រុស អាយុ២៩ឆ្នាំ និងឈ្មោះ [redacted] **យ៉ុងហ៊ួរ** (WHANG YONG HUI) ភេទប្រុស អាយុ៣៤ឆ្នាំ រងរបួសធ្ងន់ ព្រមទាំងម្ចាស់តូបលក់ដូរក្បែរកន្លែងកើតហេតុឈ្មោះ [redacted] **សារី** ភេទស្រី រងរបួសធ្ងន់។ ក្រោយពីកើតហេតុសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកបាទី បានចុះពិនិត្យវាស់វែងកន្លែងកើតហេតុ និងដកហូតវត្ថុតាង និងកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

**-ជនជាប់ចោទឈ្មោះ**[redacted] **ភារម្យ បានឆ្លើយថា:** កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ខ្លួនបានបើកឡាន ម៉ាកដេវូ ពណ៌ត្រអ៊ី ពាក់ស្លាកលេខ ភ្នំពេញ3A-3836 នៅលើផ្លូវជាតិលេខ៣ ក្នុងគោលដៅ ពីភ្នំទទា ទៅរាជធានីភ្នំពេញ ក្នុងល្បឿន៤៥ គីឡូម៉ែត្រក្នុងមួយម៉ោង។ លុះដល់ចំណុចកើតហេតុ គឺព្រំប្រទល់ឃុំសូភី និងឃុំតាំងដូង ស្រុកបាទី ស្រាប់តែខ្លួន បានឃើញម៉ូតូមួយគ្រឿង មិនចាំស្លាកលេខ ពណ៌ក្រហម បើកបរដោយមនុស្សស្រីម្នាក់ បញ្ច្រាសផ្លូវហើយបត់ចូលមកមុខឡានរបស់ខ្លួន។ ឃើញដូចនេះខ្លួនក៏បានជាន់ហ្វ្រាំង គេចរួច



Scanned with CamScanner

ពីម៉ូតូនោះចូលទៅគន្លងផ្លូវម្ខាងទៀត។ ពេលនោះមានរថយន្តម៉ាកតូយូតាវីវ៉ូ ពណិស ពាក់ស្លាកលេខ ភ្នំពេញ 2BO-2620 បើកបរក្នុងល្បឿនលឿនតាមផ្លូវស្រប់របស់គេ។ ពេលឃើញដូចនេះខ្លួនបានជាន់ហ្វ្រាំងដែរ ប៉ុន្តែជាន់មិនជាប់ បណ្តាលឱ្យខ្លួនទៅបុកឡាននោះតែម្តង បានរុញរថយន្តនោះដល់ចូលទៅក្នុងតូបលក់ អ្នកលក់ចាបហួតនៅជិតនោះបណ្តាលឱ្យរបួស ចំណែកអ្នកបើកឡានវីវ៉ូ រងរបួស។ ពេលកើតហេតុភ្លាមៗ មិនបានដឹងថាមនុស្សស្លាប់ ឬរបួសនោះទេ ហើយខ្លួនមិនបានរត់ទៅចេញពីកន្លែងកើតហេតុដែរ គឺខ្លួនបានចុះពីឡាន ទៅមើលឡានដែលខ្លួនបានបុកហើយសមត្ថកិច្ចឃាត់រូបខ្លួនតែម្តង។ ខ្លួនមានប័ណ្ណបើកបរត្រឹមត្រូវ ហើយឡានដែលខ្លួនបើកគឺជាឡានរបស់ក្រុមហ៊ុនទ្រីស៊ីម៉ី ហើយមានលក្ខណៈត្រឹមត្រូវតាមបច្ចេកទេសទាំងអស់។ ខ្លួនពុំមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយក្រុមហ៊ុនទេ គ្រាន់តែបើកឡានឱ្យក្រុមហ៊ុន ហើយក្រុមហ៊ុនបានផ្តល់ប្រាក់ខែចំនួន USD២០០(ពីររយ) ដុល្លារអាមេរិកក្នុងមួយខែ។ ខ្លួនពុំដឹងទេថាឡានរបស់ក្រុមហ៊ុន ទ្រីស៊ីម៉ី ពាក់ស្លាក់លេខភ្នំពេញ 3A-3836 មានប័ណ្ណប៉ាតង់ ឬក៏មានឈៀក នោះទេ ប៉ុន្តែឡានមិន ស្លាកសញ្ញា(Logo) របស់ក្រុមហ៊ុនទ្រី ស៊ីវម៉ី ច្បាស់សាល់ត្រឹមត្រូវ។

**-អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] សារ៉ន បានឆ្លើយថា:** កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង៤ និង៣០នាទីល្ងាច នៅចំណុចភូមិតាំងដូង ឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ មានរថយន្តដឹកដីមួយគ្រឿងទម្ងន់ប្រហែល២៥តោន បើកបរពីទិសខាងត្បូងទៅទិសខាងជើងក្នុងល្បឿនលឿន ហើយក៏បានរេចង្កូតទៅខាងឆ្វេងដៃបានបុករថយន្តតូចម៉ាកតូយ៉ូតាពណិស ដែលមានស្លាកលេខ ភ្នំពេញ 2BO-2620 ហើយក៏បានបុកអូសរថយន្តនោះប្រហែល២០ម៉ែត្រ ហើយរុញរថយន្តតូចទៅប៉ះរបាំងស្ពាន ហើយ ជ្រុលបុកតូបប្អូនស្រីខ្លួនបណ្តាលឱ្យរបួសធ្ងន់ធ្ងរ និងខូចខាងសម្ភារៈគ្រឿងទេសជាច្រើន និងតូបលក់គ្រឿងទេសក៏ខ្ទេចខ្ទីអស់ទាំងស្រុង ចំណែកប្អូនស្រីខ្លួនបានរងរបួសធ្ងន់កំពុងសម្រាកនៅមន្ទីពេទ្យនៅឡើយ។ ខ្លួនសូមប្តឹងទាមទារសំណងថ្លៃព្យាបាល និងថ្លៃខូចខាត ព្រមទាំងសំណងជម្ងឺចិត្តចំនួន១៥.000 (មួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) និងសុំឱ្យតុលាការផ្តន្ទាទោសជនត្រូវចោទតាមផ្លូវច្បាប់។

**-អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ភាស់ បានឆ្លើយថា:** កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១៧ និង៣៥នាទី នៅចំណុចផ្លូវជាតិលេខ៣ស្ថិតនៅភូមិតាំងដូង ឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ មានរថយន្តមួយគ្រឿងម៉ាកដេវ៉ូ ដែលបើកបរពីទិសខាងត្បូងទៅទិសខាងជើងក្នុងល្បឿនលឿន បានបុករថយន្តប្តី ខ្លួនកំពុងតែជិះពេញមួយទំហឹងតែម្តងបណ្តាលឱ្យប្តីខ្លួនស្លាប់នៅកន្លែងកើតហេតុតែម្តង ឈ្មោះ[redacted] ស្មី ភេទប្រុស អាយុ២២ឆ្នាំ គឺជាប្តីខ្លួន មុខរបរបើកបរ រស់នៅភូមិគុសថ្មី ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្លួនកើតទុកមិនសុខចិត្តសុំប្តឹងទាមទារឱ្យតុលាការផ្តន្ទាទោសអ្នកបើកបរតាមផ្លូវច្បាប់ និងទាមទារទឹកប្រាក់ចាត់ចែងធ្វើពិធីបុណ្យសពចំនួន ១០,000$ (មួយម៉ឺនដុល្លាអាមេរិក)។

**-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ[redacted] កញ្ញារិទ្ធ បានឆ្លើយថា:** ខ្លួនគឺជាម្ចាស់ឡាន ម៉ាកត្រេអ៊ី ពាក់ស្លាកលេខ ភ្នំពេញ 3A-៣៨៣៦ ខ្លួនជាអ្នកជ្រើរើសតៃកុងឡាន សម្រាប់បើកបរដឹកដីឱ្យក្រុមហ៊ុនទ្រីស៊ីវម៉ី ដែកដឹកពីភ្នំពេញ ទៅផ្លូវ៦០ ម៉ែត្រ រាជធានីភ្នំពេញ ដោយឱ្យប្រាក់ខែគោលក្នុងមួយខែ១៥0 ដុល្លារអាមេរិក និងប្រាក់ជើង ក្នុងមួយជើង១៥ (ដប់ប្រាំដុល្លារអាមេរិក)។ ឈ្មោះ [redacted]ភារម្យ បានមកសុំខ្លួនបើកឡានដឹកដី ហើយខ្លួនក៏បានឱ្យប្រាក់ខែដូចការជ្រើសរើស។ លុះនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្រាប់តែឈ្មោះ ធី ភារម្យ បានបើកឡាន របស់ខ្លួនទៅជួបគ្រោះថ្នាក់ចរាចរណ៍ នៅស្រុកបាទី ខេត្តតាកែវ ជាមួយរថយន្ត ម៉ាកតូ

យូតារីវ៉ូ បណ្តាលឱ្យមានមនុស្សស្លាប់ និងរបួស។ មកទល់នឹងពេលនេះខ្លួនពុំមានលទ្ធភាពសងសំណងទៅជនរងគ្រោះទេ ព្រោះឡានដែលឈ្មោះ ធី ភារម្យ បើកគឺខ្លួនជាអ្នកបង់រំលោះ សូមតុលាការមេត្តាធ្វើតាមច្បាប់។

**-សេចក្តីសន្និដ្ឋានការពារសិទ្ធិរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងក្រុមហ៊ុន** CHINA ROAD BRIDGE COPORARION (CRBC) ដែលមាអាសយដ្ឋាន# 445 Phnom Penh Tower ជាន់ទី១៩ ផ្លូវព្រះមុនីវង្ស(៩៣) កែងផ្លូវលេខ២៣២ ភូមិ១ សង្កាប់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ដោយមានលោក ZHOU YONG ជាអ្នកតំណាង និងក្រុមហ៊ុន ធានារ៉ាប់រង **ភីភិល &ជាតន័រ អ៊ិនសួរេន ភីអិលស៊ី** មានអាសយដ្ឋានផ្ទះលេខ៣៨ ផ្លូ៣២២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានលោក [redacted] **ហាមិត្ត** ជានាយកប្រតិបត្តតំណាងឱ្យក្រុមហ៊ុន ថាៈ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១៧ និង៣៥នាទី ឈ្មោ[redacted] **ភារម្យ** ភេទប្រុស អាយុ៣៥ឆ្នាំ បានបើកបររថយន្តមួយគ្រឿង ម៉ាក ដេវ៉ូពណ៌គ្រេអ៊ី ពាក់ស្លាកលេខភ្នំពេញ 3A-3836 ចេញពីក្រុមហ៊ុនឡានដឹកដីក្នុងគោលបំណងទៅរាជធានីភ្នំពេញ នៅលើផ្លូវជាតិលេខ៣ លុះដល់ចំណុចចន្លោះគីឡូម៉ែត្រលេខ ៤១-៤២ ស្ថិតនៅភូមិតាំងដូង ស្រុកបាទី ខេត្តតាកែវ អ្នកបើកបររថយន្តធន់ធ្ងន់ខ្វះការប្រុងប្រយ័ត្នក៏បានបុករថយន្តម៉ាកតូយ៉ូតា ពាក់ស្លាកលេខភ្នំពេញ 2BO-2620 ដែលបើកបរដោយឈ្មោះ[redacted]**ស្មី** បណ្តាលឱ្យស្លាប់នៅនឹងកន្លែងកើតហេតុឈ្មោះ [redacted] **លាង** ភេទប្រុស បានស្លាប់នៅពេលដែលដឹកមន្ទីរពេទ្យ និងឈ្មោះ Wang Yong Hui ភេទប្រុស ជនជាតិចិន រងរបួសធ្ងន់ ដែលជាបុគ្គលិករបស់ក្នុងហ៊ុន CHINA ROAD AND BRIDGE COPORATION (CRBE)។ ក្នុងរឿងនេះប្តឹទាមទារសំណងជំងឺចិត្ត ថ្លៃថ្នាំព្យាបាលរបួសចំនួន ១២០,០០០ (ដប់បពីរម៉ឺនដុល្លារអាមេរិក)។ ខ្លួនស្នើសុំឱ្យតុលាការមេត្តាសម្រេចអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺម្ចាស់ក្រុមហ៊ុនទ្រីស៊ីវម៉ី ដែលម្ចាស់រថយន្តឈ្មោះ [redacted] **លីមហួង** ទទួលខុសត្រូវចំពោះ សកម្មភាពរបស់នយោជិតរបស់ខ្លួនដែលជាបើកបររថយន្តបង្ក និងសូមតុលាការសម្រេចអំពីសំណងតាមការទាមទារ។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា:** សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** ស្តែងឡើងអំពីការធ្វេសប្រហែស ក្នុងការបើកបរទើបបណ្តាលឱ្យមានរបួសដល់អ្នកដទៃ និងមានជនរងគ្រោះឈ្មោះ[redacted] **រស្មី** ឈ្មោះ [redacted] **លាង** បានទទួលមរណភាព ហើយថែមទាំងខូចរថយន្តបង្ក និងរថយន្តរងគ្រោះ ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតបុគ្គល ខូចខាតទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និង និង សន្តិសុខសង្គមជាខ្លាំង និងជាអំពើដែលច្បាប់បានហាមឃាត់។ ដូចនេះតំណាងអយ្យការធ្វើការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនខាងលើនេះតាមបញ្ញត្តិច្បាប់ និងរក្សាបទចោទប្រកាន់ក្នុងដីកាសន្និដ្ឋានស្ថាពរដដែល។

**-ជនជាប់ចោទបាននិយាយសំដីចុងក្រោយថា:** សូមតុលាការមេត្តាបន្ធូរបន្ថយទោស ដល់រូបខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ និងសន្យាថាចេញទៅវិញកែខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ



Scanned with CamScanner

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ ។

## តុលាការខេត្តតាកែវ

## យល់ឃើញថា

១-យោងតាមរបាយការណ៍លេខ: **០៦២/០២២** ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២ របស់ស្នងការដ្ឋាននគរបាលខេត្តតាកែវ ក៏ដូចជាភស្តុតាងនានាក្នុងសំណុំរឿង ឃើញថាពិតជាមានអង្គហេតុ បើកបរធ្វេសប្រហែសខ្ជីខ្ជារម មិនប្រុងប្រយ័ត្នបណ្តាលរបួស និងស្លាប់អ្នកដទៃ ស្ថិតនៅភូមិតាំងដូង ឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០២២ ប្រព្រឹត្តដោយឈ្មោះ[redacted] **ភារម្យ** ប្រាកដមែន ។

**២**-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** ថា: កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ខ្លួនពិតជាបាន បើបរឡានម៉ាកដេវូគ្រេអ៊ី ពាក់ស្លាកលេខភ្នំពេញ 3A-3836 នៅលើផ្លូវជាតិលេខ ៣ ទៅបុកឡានពាក់ស្លាកលេខ ២BO-២៦២០ ដែលបើរដោយឈ្មោះ [redacted] **ស្មី** ហើយបណ្តាលឱ្យអ្នកបើកបរស្លាប់ប្រាកដមែន។ ការបើកបរបណ្តាលឱ្យអ្នកដទៃរបួស និងស្លាប់នេះខ្លួនពុំមានចេតនា។ ចម្លើយនេះ ពិតបង្ហាញឱ្យឃើញថា ជនត្រូវចោទមានការធ្វេសប្រហែសក្នុងការបើកបររថយន្ត បានបណ្តាលជនគ្រោះឈ្មោះ [redacted] **ស្មី** និងជនរងគ្រោះឈ្មោះ [redacted] **លាង** ស្លាប់ ហើយបានបង្កឱ្យជនរងគ្រោះឈ្មោះ **យ៉ាន យ៉ុងហួ** រងរបួសធ្ងន់។ គប្បីតុលាការទទួលមកពិចារណា។

**៣**-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** ថា: ចំពោះការដែលខ្លួនបើកបរហើយវេចង្កូតទៅបុកឡានរបស់ជនគ្រោះ មូលហេតុនៅពេលខ្លួនកំពុងបើកបរលើផ្លូវជាតិលេខ:៣ ត្រង់ចំណុចគីឡូម៉ែត្រលេខ ៤១-៤២ ស្ថិតនៅចន្លោះឃុំតាំងដូង និងឃុំសូភី ស្រុកបាទី ស្រាប់តែមានម៉ូតូមួយគ្រឿង ខ្លួនមិនចាំស្លាកលេខ ពណ៌ក្រហម បើកបរ ដោយមនុស្សស្រីម្នាក់ បញ្ច្រាសទិសហើយបត់ចូលមុខឡានរបស់ខ្លួន។ ពេលនោះខ្លួនបានជាន់ហ្វ្រាំង គេចពីម៉ូតូនោះ ចូលទៅផ្លូវម្ខាងទៀត ក៏មានរថយន្តម៉ាកតូយូតាវីវី ពណ៌សពាក់ស្លាកលេខភ្នំពេញ 2BO-2620 ហើយខ្លួនបានជាន់ហ្វ្រាំងដែរ ប៉ុន្តែជាន់មិនជាប់ ហើយបានបុករថយន្តនោះតែម្តង។ តាមកំណត់ហេតុត្រួតពិនិត្យកន្លែងកើតហេតុ និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted] **ភារម្យ** ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឱ្យអ្នករបួស និងស្លាប់អ្នកដទៃ**។ គប្បីតុលាការសម្រេចផ្តន្ទាទោសជននេះតាមបញ្ញត្តិច្បាប់ជាធរមាន។

៤-ចម្លើយរបស់ដើមបណ្តឹងឈ្មោះ[redacted] **សារ៉ន** ថា ក្នុងរឿងនេះខ្លួនសូមប្តឹងទាមទារសំណងជំងឺចិត្ត ថ្លៃថ្នាំព្យាបាលរបួសចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក)។ គប្បីតុលាការលើកយកបញ្ហាសំណងរដ្ឋប្បវេណីមកពិចារណា និងសម្រេចតាមស្ថានភាពជាក់ស្តែង។

៥-លោកមេធាវីឈ្មោះ [redacted] និងលោកមេធាវីឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា: ចំពោះឈ្មោះ **អ៊ុក កញ្ញារិទ្ធ** មិនមែនជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេព្រោះ រថយន្តបង្កគឺមានឈ្មោះ [redacted] **លីហួង** ជាម្ចាស់កម្មសិទ្ធិករ មិនតែប៉ុណ្ណោះជនជាប់ចោទឈ្មោះ[redacted] **ភារម្យ** បានសារភាពថាខ្លួនបើកឡាន ឱ្យក្រុមហ៊ុនទ្រីស៊ីវម៉ី ប៉ុន្តែគ្មានកិច្ចសន្យាការងារទេ។ ចំណែកម្ចាស់ឡាន ពិតប្រាកដគឺខ្លួនពុំស្គាល់នោះទេ។ ការកត់សម្គាល់របស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមហ៊ុន CHINA ROAD AND BRIDGE COPORATION (CRBE) ពុំមានភស្តុតាង បញ្ជាក់បានឡើយ។ ម៉្យាងវិញទៀតមានភាពផ្ទុយគ្នា ការអះអាងរបស់ឈ្មោះ [redacted]



Scanned with CamScanner

កញ្ញារិទ្ធថារថយន្តបង្កគឺជារបស់ខ្លួនដែលបានទិញពីឈ្មោះ ហាំង លីហួង ប៉ុន្តែពុំទាន់បានកាត់ឈ្មោះ ទេ ការអះអាងដូចគ្នា នឹងភស្តុតាង គឺលិខិត **លក់ និងទិញ**រថយន្ត ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ រវាងឈ្មោះ [redacted] **លីហួង** និងឈ្មោះ [redacted] **កញ្ញារិទ្ធ ដែរ**។ គប្បីតុលាការធ្វើការពិចារណា។

៦-តាមចម្លើយរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] **កញ្ញារិទ្ធ** ថា: ឡានដែលឈ្មោះ [redacted] **ភារម្យ** បើកបរគឺជារបស់ខ្លួន ហើយខ្លួនជាអ្នកបើកប្រាក់ខែឱ្យទៅឈ្មោះ [redacted] **ភារម្យ** ក្នុងខែ១៥០ (មួយរយហាសិបដុល្លារអាមេរិក) មកដល់ពេលខ្លួនពុំមានលទ្ធភាពក្នុងការទូទាត់សំណងទៅឱ្យជនរងគ្រោះទេ។ គប្បីតុលាការទទួលមកពិចារណា។

**៧**-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** ត្រូវបានច្បាប់កំណត់ជាបទល្មើស **បើកបរដោយធ្វេសប្រហែស ខ្វីខ្វា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួស និងស្លាប់អ្នកដទៃ** ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

៨-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** មិនត្រឹមតែបង្កឱ្យមានការប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់ និងសន្តិសុខសង្គមប៉ុណ្ណោះទេ អំពើនេះបង្កឱ្យមានភាពចលាចលក្នុងសង្គមទៀតផង។ គប្បីតុលាការសម្រេចផ្តន្ទាទោសជននេះតាមច្បាប់។

**៩**-ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** មានអាយុ៣៦ឆ្នាំ ជានីតិជន មិនមានសញ្ញាណណាមួយ បញ្ជាក់ពីបញ្ហាវិបល្លាសស្មារតីទេ ជាមនុស្សអាចយល់ដឹងនូវព្យសនកម្មដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួនបាន ប៉ុន្តែបែរជាប្រព្រឹត្តអំពើល្មើសដែលច្បាប់បានហាមឃាត់ទៅវិញ ។

**១០**-ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តតាកែវ តាមដីកាសម្រេចលេខ:២៤៥ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២ ។ តាមការគណនាដោយគិតចាប់ពីថ្ងៃឃុំខ្លួនរហូតដល់ថ្ងៃប្រកាសសាលក្រមថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ជននេះបានទទួលរងការឃុំខ្លួនអស់រយ:ពេល១០ខែ និងថ្ងៃ១៧(ដប់ខែ និងដប់ប្រាំពីរថ្ងៃ)។

**១១**-សេចក្តីសន្និដ្ឋានរបស់មេធាវីការការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ថា កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១៧ និង៣៥នាទី ឈ្មោះ [redacted] **ភារម្យ** ភេទប្រុស អាយុ៣៥ឆ្នាំ បានបើកបររថយន្តមួយគ្រឿង ម៉ាកដេវ៉ូពណ៌ត្រែអ៊ី ពាក់ស្លាកលេខភ្នំពេញ 3A-3836 ចេញពីក្រុមហ៊ុនឡានដឹកដីក្នុងគោលបំណងទៅរាជធានីភ្នំពេញ នៅលើផ្លូវជាតិលេខ៣ លុះដល់ចំណុចចន្លោះគីឡូម៉ែត្រលេខ ៤១-៤២ ស្ថិតនៅភូមិតាំងដូង ស្រុកបាទី ខេត្តតាកែវ អ្នកបើកបររថយន្តធន់ធ្ងន់ខ្វះការប្រុងប្រយ័ត្នក៏បានបុករថយន្តម៉ាកតូយ៉ូតាពាក់ស្លាកលេខភ្នំពេញ 2BO-2620 ដែលបើកបរដោយឈ្មោះ [redacted] **រស្មី** បណ្តាលឱ្យស្លាប់នៅនឹងកន្លែងកើតហេតុឈ្មោះ [redacted] **លាង** ភេទប្រុស បានស្លាប់នៅពេលដែលដឹកមន្ទីរពេទ្យ និងឈ្មោះ Wang Yong Hui ភេទប្រុស ជនជាតិចិន រងរបួសធ្ងន់ ដែលជាបុគ្គលិករបស់ក្នុងក្រុមហ៊ុន CHINA ROAD AND BRIDGE COPORATION (CRBE)។ ក្នុងរឿងនេះប្តឹទាមទារសំណងជំងឺចិត្ត ថ្លៃថ្នាំព្យាបាលរបួសចំនួន ១២០,០០០ (ដប់បពីរម៉ឺនដុល្លារអាមេរិក)។ ខ្លួនស្នើសុំឱ្យតុលាការមេត្តាសម្រេចអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺម្ចាស់ក្រុមហ៊ុនទ្រីស៊ីវម៉ី ដែលម្ចាស់រថយន្តឈ្មោះ [redacted] **លីមហួង** ទទួលខុសត្រូវចំពោះ សកម្មភាពរបស់នយោជិតរបស់ខ្លួនដែលជាបើកបរឡានបង្ក និងសូមតុលាការសម្រេចអំពីសំណងតាមការទាមទារ។ គប្បីតុលាការទទួលមកពិចារណា។



Scanned with CamScanner

**១២**-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ថា: សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** ស្តែងឡើងអំពីការធ្វេសប្រហែស ក្នុងការបើកបរទើបបណ្តាលឱ្យមានរបួសដល់អ្នកដទៃ និងមានជនរងគ្រោះឈ្មោះ [redacted]**រស្មី** ឈ្មោះ [redacted] **លាង** បានទទួលមរណភាព ហើយថែមទាំងខូចរថយន្តបង្ក និងរថយន្តរងគ្រោះ ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតបុគ្គល ខូចខាតទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និង និងសន្តិសុខសង្គមជាខ្លាំង និងជាអំពើដែលច្បាប់បានហាមឃាត់។ ដូចនេះតំណាងអយ្យការធ្វើការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនខាងលើនេះតាមបញ្ញត្តិច្បាប់ និងរក្សាបទចោទប្រកាន់ក្នុងដីកាសន្និដ្ឋានស្ថាពរដដែល។ សេចក្តីសន្និដ្ឋាននេះមានមូលដ្ឋានច្បាស់លាស់គប្បីតុលាការទទួលមកពិចារណា និងសម្រេចដោយផ្អែកតាមអង្គហេតុ និងធាតុផ្សំនៃបទល្មើស។

**១៣**-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ[redacted] **ភារម្យ** ថាសូមឱ្យតុលាការបន្ធូរបន្ថយទោសដល់រូបខ្លួនផង ខ្លួនដឹងកំហុសហើយ។ គប្បីតុលាការទទួលមកពិចារណា ។

**១៤**-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលនាំឱ្យមានពិរុទ្ធភាពលើឈ្មោះ [redacted] **ភារម្យ** (អត្តសញ្ញាណខាងលើ) ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួស និងស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅភូមិតាំងដូង ឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ និងមាត្រា៨៥ នៃច្បាប់ស្តីចរាចរណ៍ផ្លូវគោក ។

## ហេតុដូច្នេះតុលាការ

## សម្រេចសេចក្តី

**១- ផ្តន្ទាទោស** ជនជាប់ចោទឈ្មោះ[redacted] **ភារម្យ** ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ **២ឆ្នាំ (ពីរឆ្នាំ)** គត់ ប៉ុន្តែទោសនេះត្រូវអនុវត្តទោសនៅក្នុងពន្ធនាគារចំនួន**១(មួយឆ្នាំ)** ទោសដែលនៅសល់ត្រូវព្យួរទោសធម្មតាតាមបញ្ញត្តិមាត្រា១០៤ មាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។

ពីបទ:**បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួស និងស្លាប់អ្នកដទៃ** តាមបញ្ញត្តិមាត្រា**៨៣** និងមាត្រា**៨៥** នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោ។

ប្រព្រឹត្តនៅភូមិតាំងដូង ឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។

**២-បង្គាប់ឱ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ** [redacted] **កញ្ញារិទ្ធ** សងសំណងជំងឺចិត្ត ថ្លៃខូចខាត ថ្នាំព្យាបាលរបួសទៅៈ

-ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារិន** ចំនួន ៦០.០០០.០០០(ហុកសិបលានរៀល)

-ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **ភាស់** ចំនួន ៤០.០០០.០០០(សែសិបលានរៀល)

-ឱ្យដើមបណ្តឹងរដ្ឋប្បវេណី **ក្រុមហ៊ុន CHINA ROAD BRIDGE COPORARION (CRBC)** ដែលមានអាសយដ្ឋាន# 445 Phnom Penh Tower ជាន់ទី១៩ ផ្លូវព្រះមុនីវង្ស(៩៣) កែងផ្លូវលេខ២៣២ ភូមិ១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ដោយមានលោក ZHOU YONG ជាអ្នកតំណាង និងក្រុមហ៊ុន ធានារ៉ាប់រង **ភីភល &ជាតន័រ អ៊ិនស្សូរេន ភីអិលស៊ី** មានអាសយដ្ឋានផ្ទះលេខ៣៨ ផ្លូវ៣២២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ សរុបចំនួន **៤០០.០០០.០០០**(បួនរយលានរៀល)



Scanned with CamScanner

ដើមបណ្ដឹងរដ្ឋប្បវេណីទាមទារលើសពីនេះបដិសេធចោល។

**សាលក្រមនេះ** ជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តតាកែវ កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣។

ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ភារម្យ**។ កំបាំងមុខដើមបណ្ដឹងឈ្មោះ [redacted] **សារ៉ន** ឈ្មោះ [redacted] **កាស់** និងឈ្មោះ [redacted] **យ៉ុងហួល**។ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] **កញ្ញារិទ្ធ**។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ១៤ រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦

តាកែវ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

(ហត្ថលេខា និងត្រា)

[redacted]

**ចៅក្រមជំនុំជម្រះ**

(ហត្ថលេខា និងត្រា)

[redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤ រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦

តាកែវ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]